# សេចក្តីថ្លែងការណ៍រួម

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥

# អង្គការសង្គមស៊ីវិល សូមថ្កោលទោសចំពោះការបង្ក្រាបទៅលើគណបក្សជំទាស់ និងបង្ហាញក្តីបារម្ភចំពោះការគំរាមកំហែងដល់លទ្ធិប្រជាធិបតេយ្យ

យើងខ្ញុំដែលជាអង្គការសង្គមស៊ីវិលដែលមានរាយនាមខាងក្រោម សូមថ្កោលទោសចំពោះការបង្ក្រាបធ្ងន់ធ្ងររបស់រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ទៅលើគណបក្សជំទាស់ ព្រមទាំងការត្រួតត្រាហួសហេតុទៅលើប្រព័ន្ធតុលាការពីសំណាក់រដ្ឋាភិបាលក្នុងគោលបំណងយាយីទៅលើគូបដិបក្ខរបស់ខ្លួន។

នៅថ្ងៃសុក្រ ទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ សាលាដំបូងរាជធានីភ្នំពេញបានចេញដីកាចាប់ខ្លួនលោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ ("គ.ស.ជ") ដែលនេះបង្ហាញយ៉ាងច្បាស់ពីចលនាមួយក្រោមហេតុផលនយោបាយ។ នៅថ្ងៃច័ន្ទ ទី១៦ ខែវិច្ឆិកានេះ មេដឹកនាំគណបក្សជំទាស់ត្រូវបានគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ដកហូតតំណែងជាសមាជិករដ្ឋសភារបស់លោក ដោយយោងទៅលើដីកាចាប់ខ្លួន។ នេះជាការវិវត្តន៍ចុងក្រោយបង្អស់ចំពោះការចាប់ខ្លួន ការកាត់ទោស ការគំរាមកំហែង និងការវាយដំជាបន្តបន្ទាប់ពីសំណាក់រដ្ឋាភិបាលទៅលើគណបក្សជំទាស់នៅប៉ុន្មានខែថ្មីៗនេះ។ ការបង្ក្រាបនេះបង្ហាញពីការគំរាមកំហែងធ្ងន់ធ្ងរទៅលើលទ្ធិប្រជាធិបតេយ្យ និងសេរីភាពមូលដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ដីកាចាប់ខ្លួនដែលចេញកាលពីថ្ងៃសុក្រពាក់ព័ន្ធទៅនឹងករណីចោទប្រកាន់ពីបទបរិហារកេរ្តិ៍ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសនៅក្នុងឆ្នាំ២០១១ ដោយសារតែលោក សម រង្ស៊ី បានធ្វើសុន្ទរកថាមួយក្នុងឆ្នាំ២០០៨។ ការលេចឡើងជាថ្មីនូវដីកាចាប់ខ្លួនភ្លាមៗចំពោះការកាត់ទោសលើករណីនេះ ដែលបានកើតឡើងជាង ៧ ឆ្នាំកន្លងមក កើតឡើងផ្ទួនៗគ្នាជាមួយនឹងការគំរាមកំហែងផ្លូវច្បាប់ជាច្រើនលើកច្រើនសាររបស់លោកនាយករដ្ឋមន្ត្រីនាសប្តាហ៍ថ្មីៗនេះចំពោះលោក សម រង្ស៊ី ។ ការចេញដីកានេះបង្ហាញយ៉ាងច្បាស់ដោយសារហេតុផលនយោបាយ ព្រមទាំងជាឧទាហរណ៍មួយផ្សេងទៀតនៃការត្រួតត្រារបស់រដ្ឋាភិបាលទៅលើប្រព័ន្ធតុលាការកម្ពុជាដែលត្រូវបានបន្តប្រើប្រាស់ជាឧបករណ៍ដើម្បីបន្ទប់បង្អាក់ដល់សម្លេងជំទាស់នៅកម្ពុជា។

នេះគឺជាការវិវត្តន៍ចុងក្រោយបង្អស់នៃវិធានការនានារបស់រដ្ឋាភិបាលប្រឆាំងទៅលើគណបក្សជំទាស់ដែលរំលោភទៅលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ នគរបាលខកខានក្នុងការទប់ស្កាត់ករណីវាយប្រហារដ៏ឃោរឃៅទៅលើតំណាងរាស្ត្រគណបក្សជំទាស់ លោក ញ៉យ ចំរើន និងលោក គង់ សភា នៅខាងក្រៅវិមានរដ្ឋសភាពីសំណាក់អ្នកគាំទ្រគណបក្សប្រជាជនកម្ពុជា("ប្រ.ជ") ខណៈដែលមានភស្តុតាងបង្ហាញថាការវាយប្រហារនោះត្រូវបានជួយសម្រួល ឬរៀបចំឡើងដោយមន្ត្រីជាន់ខ្ពស់។ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥ សមាជិកព្រឹទ្ធសភាគណបក្សជំទាស់ លោក ហុង សុខហួរ ត្រូវបានចាប់និងឃុំខ្លួន បើទោះបីជាលោកមានអភ័យឯកសិទ្ធិរួចផុតពីការចាប់ខ្លួនក៏ដោយ ដោយសារតែលោកបានបង្ហោះសន្ធិសញ្ញាព្រំដែនក្លែងក្លាយនៅលើបណ្តាញសង្គមហ្វេសប៊ុក។ លោកកំពុងស្ថិតនៅក្នុង

ការឃុំខ្លួននៅឡើយ។ កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ សកម្មជន គ.ស.ជ ចំនួន ១១ រូប ត្រូវបានសាលាដំបូងរាជធានីភ្នំពេញកាត់ទោសដាក់ពន្ធនាគាររយៈពេលពីចន្លោះ ៧ ឆ្នាំ ដល់ ២០ ឆ្នាំ ពាក់ព័ន្ធនឹងការតវ៉ាដែលបានកើតឡើងក្នុងខែកក្កដា ឆ្នាំ២០១៤ នៅទីលានប្រជាធិបតេយ្យក្នុងរាជធានីភ្នំពេញ។ ការជំនុំជម្រះក្ដីធ្វើឡើងដោយផ្អែកតាមភស្តុតាងចោទប្រកាន់សិប្បនិម្មិត និងមិនបានគោរពដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទាល់តែសោះ។ ឧទាហរណ៍ទាំងនេះបានប៉ះពាល់ដល់គោលការណ៍ឯករាជ្យភាពនៃប្រព័ន្ធតុលាការ និងសិទ្ធិមនុស្សជាសកលក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

ការបង្ក្រាបទៅលើគណបក្សជំទាស់នេះធ្វើឡើងផ្ទុយស្រឡះជាមួយនឹងព្រឹត្តិការណ៍នាពេលថ្មីៗនេះនៅប្រទេសមីយ៉ាន់ម៉ា ខណៈដែលការគ្រប់គ្រងបែបផ្ដាច់ការកំពុងតែបើកផ្លូវដើម្បីឲ្យមានការលូតលាស់លទ្ធិប្រជាធិបតេយ្យ។ ផ្ទុយទៅវិញ លទ្ធិប្រជាធិបតេយ្យនៅកម្ពុជាកំពុងត្រូវបានបំផ្លាញបន្តិចម្ដងៗ។ លទ្ធិប្រជាធិបតេយ្យពិតប្រាកដទាមទារឱ្យមានការគោរពដោយពេញលេញនូវសិទ្ធិជួបប្រជុំដោយសន្តិវិធី សិទ្ធិខាងបញ្ចេញមតិ និងការបង្កើតសមាគម ព្រមទាំងការបែងចែកអំណាចនិងការគោរពនីតិរដ្ឋពិតប្រាកដ។ ការចេញដីកាចាប់ខ្លួនលោក សម រង្ស៊ី ជាការរំលោភបំពានដល់ដល់គោលការណ៍ឯករាជ្យភាពនៃប្រព័ន្ធតុលាការ និងគោលការណ៍នៃការបែងចែកអំណាច។ ប្រទេសមីយ៉ាន់ម៉ាដែលប្រទេសជិតខាងរបស់យើងបានធ្វើអន្តរកាលឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ ដែលនេះបង្ហាញថាអ្នកនយោបាយនៅប្រទេសកម្ពុជាមានចេតនាបំបិទលទ្ធិប្រជាធិតេយ្យទាំងស្រុងនៅក្នុងប្រទេស។ ការកំណត់គោលដៅប្រឆាំងទៅលើតំណាងរាស្ត្រគណបក្សជំទាស់ជាប្រព័ន្ធដោយប្រាស់ចាករដ្ឋធម្មនុញ្ញដូច្នេះ គឺជាការផ្ទុយទាំងស្រុងទៅនឹងដំណើរការលទ្ធិប្រជាធិបតេយ្យ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

យើងខ្ញុំជាអង្គការសង្គមស៊ីវិលមានរាយនាមដូចខាងក្រោម សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាមេបញ្ឈប់ការត្រួតត្រាដោយហេតុផលនយោបាយទៅលើប្រព័ន្ធតុលាការ និងទុកឱកាសឱ្យលទ្ធិប្រជាធិបតេយ្យរីកលូតលាស់នៅកម្ពុជា។

បន្ថែមពីនេះ យើងខ្ញុំសូមអំពាវនាវដល់ ប្រ.ជ និង គ.ស.ជ ព្រមទាំងអ្នកគាំទ្រនៃគណបក្សទាំងពីរមេត្តារក្សានូវភាពអត់ធ្មត់ និងបញ្ចៀសឱ្យខានតែបាននូវសកម្មភាពហិង្សាណាមួយដែលធ្វើឱ្យស្ថានការណ៍នយោបាយកាន់តែធ្ងន់ធ្ងរ។

ជាចុងបញ្ចប់ យើងខ្ញុំសូមអំពាវនាវដល់សហគមន៍អន្តរជាតិ និងម្ចាស់ជំនួយមកលើប្រទេសកម្ពុជាដាក់សម្ពាធដល់រដ្ឋាភិបាលកម្ពុជាឱ្យដោះស្រាយករណីលោក សម រង្ស៊ី តាមរយៈការចចារដោយសន្តិវិធី និងបញ្ឈប់ការប្រើប្រាស់តុលាការក្នុងការរារាំងគណបក្សជំទាស់។

អង្គការសង្គមស៊ីវិលដែលគាំទ្រសេចក្តីថ្លែងការណ៍រួមនេះ រួមមាន ៖

| *ល.រ* | *ឈ្មោះ* | *ឈ្មោះ* | *លេខទូរស័ព្ទ* |
|---|---|---|---|
| 1 | *ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)* | *កញ្ញា ស្រី សុជាវី* | 017 990 371 |
| 2 | *មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)* | *លោកស្រី ចក់ សុភាព* | 011 94 32 13 |

| | | | |
|---|---|---|---|
| 3 | *គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធ៌ម នៅ កម្ពុជា (COMFREL)* | *លោក គល់ បញ្ញា* | 012 942 017 |
| 4 | *សម្ព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)* | *លោក ស ម៉ូរ៉ា* | 016 525 781 |
| 5 | *សមាគមអាដហុកការពារសិទ្ធិមនុស្សនិងការអភិវឌ្ឍន៍នៅ កម្ពុជា (ADHOC)* | *លោក នី ចរិយា* | 011 274 959 |
| 6 | *សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម (CISA)* | *លោក ហឹម យន់* | 012 947 022 |
| 7 | *សមាគមគ្រូបង្រៀន កម្ពុជាឯករាជ្យ (CITA)* | *លោក ម៉ែ សុភក្ត្រា* | 012 351 402 |
| 8 | *សហភាពការងារកម្ពុជា (CLC*) | *លោក អាត ធន់* | 012 998 906 |
| 9 | *សម្ព័ន្ធសហគមន៍កសិករកម្ពុជា (*CCFC) | *លោក ថេង សាវឿន* | 015 225 088 |
| 10 | *អង្គការសេមធម៌កម្ពុជា (EC)* | *លោក អៀង វុទ្ធី* | 012 791 700 |
| 11 | *អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)* | *លោកស្រី រស់ សុភាព* | 012 627 857 |
| 12 | *សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)* | *លោក វន់ ពៅ* | 012 534 796 |
| 13 | *ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF)* | *លោក សៀ ភារម្យ* | 012 852 325 |
| *14* | *សមាគម ឥន្ទ្រទេវី (IDA)* | *លោកស្រី ឌី វដ្ឋា* | *012 897 161* |
| *15* | *សមាគមយុវជនខ្មែរ (KYA)* | *លោកស្រី សិទ្ធិ ហុង អៀង* | *017 788 955* |
| 16 | *មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍* | *លោក យ៉ង គឹមអេង* | 012 828 211 |
| 17 | *អង្គការពន្លកខ្មែរ* | *លោក អាង ជាតិ ឡេាម* | 012 517943 |
| 18 | *សមាគមធាងត្នោត (STT)* | *លោក អ៊ី សារុំ* | 012 836 533 |
| 19 | *អង្គការស្ត្រីខ្មែរ* | *លោកស្រី អរុណ រស្មី* | 012 236 653 |